ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០១៥.......អ.ស.ហ.ប្រ.ក.

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ៣៧០ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា

- បានឃើញប្រកាសលេខ០១៩ អ.ស.ហ.ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំលើកទី២៨ អាណត្តិទី១ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីយន្តការនៃការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាននៃការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង ក្នុងគោលដៅលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនលើរបាយការណ៍សវនកម្ម និងរបាយការណ៍ការអះអាង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនសវនកម្មនិងសវនករជារូបវន្តបុគ្គល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

បច្ចេកសព្ទដែលត្រូវបានប្រើក្នុងប្រកាសនេះមានអត្ថន័យដូចខាងក្រោម៖

- **ការត្រួតពិនិត្យគុណភាព** សំដៅដល់ការត្រួតពិនិត្យនិងវាយតម្លៃលើគុណភាពសវនកម្ម និង/ឬគុណភាពការអះអាងរបស់ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល។
- **កិច្ចសន្យាសវនកម្ម** សំដៅដល់កិច្ចសន្យាដែលធ្វើឡើងរវាងសវនករជាមួយអតិថិជន ដើម្បីធ្វើសវនកម្មលើបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់អតិថិជន។
- **កិច្ចសន្យាការអះអាង** សំដៅដល់កិច្ចសន្យាដែលធ្វើឡើងរវាងសវនករជាមួយអតិថិជន ដើម្បីផ្តល់សេវាការអះអាងស្របតាមស្តង់ដាដែលមានជាធរមាន។
- **ក្រុមហ៊ុនសវនកម្ម** សំដៅដល់សហគ្រាសដែលបានទទួលអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។
- **កម្មវិធីត្រួតពិនិត្យគុណភាព** សំដៅដល់សកម្មភាព ឬការអនុវត្តការត្រួតពិនិត្យគុណភាព ដែលត្រូវកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង(**គ.ត.ស.អ.**) រួមទាំងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀត។
- **ថ្ងៃ** សំដៅដល់បណ្តាថ្ងៃនៃប្រតិទិន រាប់ទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។
- **ថ្ងៃធ្វើការ** សំដៅដល់ថ្ងៃប្រតិទិន ដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។
- **បុគ្គលិក** សំដៅដល់និយោជិតដែលធ្វើការងារពាក់ព័ន្ធនឹងការងារសវនកម្ម ឬការងារការអះអាង។
- **មន្ត្រី** សំដៅដល់មន្ត្រីរបស់ **ន.គ.ស.** អ្នកត្រួតពិនិត្យ អ្នកអង្កេតការណ៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលមានការចាត់តាំងពី **គ.ត.ស.អ.**។

8V

- **របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព** សំដៅដល់របាយការណ៍ដែលត្រូវបានអនុម័តដោយ **គ.ត.ស.អ.**។
- **របាយការណ៍សវនកម្ម** សំដៅដល់យោបល់ ឬការបដិសេធផ្លូវការ ដែលបានចេញដោយសវនករ ជាលទ្ធផលនៃការធ្វើសវនកម្ម ឬការវាយតម្លៃដែលបានធ្វើលើនីតិបុគ្គល ឬផ្នែកណាមួយនៃនីតិបុគ្គលនោះ (ដែលហៅថា "នីតិបុគ្គលរងសវនកម្ម")។
- **របាយការណ៍ការអះអាង** សំដៅដល់របាយការណ៍ផ្លូវការដែលចេញដោយសវនករ ដើម្បីផ្តល់មតិយោបល់ឯករាជ្យ ឬការសន្និដ្ឋានលើភាពជឿជាក់ ភាពត្រឹមត្រូវ និងអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាវិជ្ជាជីវៈពាក់ព័ន្ធជាធរមាន។
- **ស្តង់ដាវិជ្ជាជីវៈ** សំដៅដល់ស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា ព្រមទាំងស្តង់ដាវិជ្ជាជីវៈផ្សេងៗដែលពាក់ព័ន្ធនឹងការបំពេញសេវាសវនកម្ម ឬសេវាការអះអាងដែលដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារជាធរមាន រួមទាំងស្តង់ដាអន្តរជាតិទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។
- **សវនករជារូបវន្តបុគ្គល** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.** និងជាដៃគូសវនកម្មដែលត្រូវបានតែងតាំងដោយក្រុមហ៊ុនសវនកម្មឱ្យទទួលខុសត្រូវចំពោះកិច្ចសន្យាសវនកម្ម ឬកិច្ចសន្យាការអះអាង និងការអនុវត្តរបស់ខ្លួន ព្រមទាំងទទួលខុសត្រូវចំពោះរបាយការណ៍សវនកម្ម និង/ឬការអះអាងដែលត្រូវបានបោះផ្សាយក្នុងនាមក្រុមហ៊ុនសវនកម្ម។
- **សេវាសវនកម្ម** សំដៅដល់សេវាត្រួតពិនិត្យនិងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យ របាយការណ៍កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុឬមិនមែនហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់គោលបំណងជាក់លាក់មួយដោយអនុលោមតាមស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជាដែលដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារជាធរមាន។
- **សេវាការអះអាង** សំដៅដល់សេវាក្រៅពីសេវាសវនកម្ម និងសេវាត្រួតពិនិត្យឡើងវិញលើប្រវត្តិសាស្ត្រ ព័ត៌មានហិរញ្ញវត្ថុ ដែលត្រូវបានអនុវត្តស្របតាមស្តង់ដាអន្តរជាតិនៃកម្ពុជាស្តីពីការអះអាង និងសេវាកម្មផ្សេងៗ។
- **អតិថិជន** សំដៅដល់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលទទួលសេវាសវនកម្ម ឬសេវាការអះអាងពីក្រុមហ៊ុនសវនកម្ម។
- **ឯកសារ** សំដៅដល់គ្រប់ព័ត៌មាន រួមមាន ឯកសារជាលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក ទិន្នន័យចងក្រងដោយកុំព្យូទ័រគ្រប់ទម្រង់ ឌីស កាសែត ខ្សែអាត់ និងគ្រប់ឧបករណ៍ផ្សេងទៀតដែលមានសំឡេង រូបភាព ឬទិន្នន័យផ្សេងៗទៀតដែលបានផ្ទុក។
- **ឯកសារសវនកម្ម ឬឯកសារការអះអាង** សំដៅដល់ឯកសារ ឬសំណុំឯកសារពាក់ព័ន្ធណាមួយដែលមានតម្រូវការចាំបាច់ប្រើប្រាស់ក្នុងអំឡុងការត្រួតពិនិត្យគុណភាព ដើម្បីជាជំនួយក្នុងការវាយតម្លៃលើការត្រួតពិនិត្យគុណភាព។ ឯកសារសវនកម្ម ឬឯកសារការអះអាង ត្រូវរាប់បញ្ចូលទាំងឯកសារពាក់ព័ន្ធនឹងកំណត់ត្រាគណនេយ្យដែលបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងឯកសារដែលទទួលបានពីប្រភពផ្សេងៗទៀត។

## ជំពូកទី២
## យន្តការនៃការត្រួតពិនិត្យគុណភាព

**ប្រការ៤.-**

ត្រូវបានបង្កើត **"គណៈកម្មាធិការត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង"** ដែលសរសេរជាអក្សរកាត់ថា "**គ.ត.ស.អ.**" ឱ្យបំពេញមុខងារជាសេនាធិការបច្ចេកទេសឱ្យនិយ័តករគណនេយ្យនិងសវនកម្ម(**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(**អ.ស.ហ.**) ដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គនាយក **ន.គ.ស.** — ប្រធាន
- អគ្គនាយករង **ន.គ.ស.** ១(មួយ)រូប — អនុប្រធាន
- ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) — អនុប្រធាន
- តំណាងធនាគារជាតិនៃកម្ពុជា២(ពីរ)រូប — សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ១(មួយ)រូប — សមាជិក
- តំណាងអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ១(មួយ)រូប — សមាជិក
- តំណាងនិយ័តករមូលបត្រកម្ពុជា ១(មួយ)រូប — សមាជិក
- តំណាងនិយ័តករបរធនបាលកិច្ច ១(មួយ)រូប — សមាជិក
- តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា ១(មួយ)រូប — សមាជិក
- តំណាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ១(មួយ)រូប — សមាជិក
- តំណាងនិយ័តករសន្តិសុខសង្គម ១(មួយ)រូប — សមាជិក
- តំណាង **វ.គ.ស.ក.** ៣(បី)រូប — សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា ១(មួយ)រូប — សមាជិក
- តំណាងនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម នៃ **ន.គ.ស.** សមាជិកនិងជាលេខាធិការ។

សមាសភាពជាក់ស្តែងនៃ **គ.ត.ស.អ.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមការស្នើរបស់អគ្គនាយកនៃ **ន.គ.ស.** ផ្អែកតាមការស្នើពីស្ថាប័នសាមី។

អនុប្រធាន និងសមាជិករបស់ **គ.ត.ស.អ.** មានអាណត្តិរយៈពេល៣(បី)ឆ្នាំ។

**គ.ត.ស.អ.** អាចបង្កើតក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តកម្មវិធីត្រួតពិនិត្យគុណភាពតាមតម្រូវការ។

**គ.ត.ស.អ.** អាចមានទីប្រឹក្សា និងអ្នកជំនាញអមសម្រាប់ជួយការងារតាមការចាំបាច់ ដែលត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមការស្នើរបស់ប្រធាន **គ.ត.ស.អ.**។

**ប្រការ៥.-**

**គ.ត.ស.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រ ផែនការសកម្មភាព ថវិកា បែបបទ នីតិវិធី និងសេចក្តីណែនាំសម្រាប់ការត្រួតពិនិត្យគុណភាព
- អនុម័តកម្មវិធីត្រួតពិនិត្យគុណភាព
- ជ្រើសរើស និងតែងតាំងក្រុមត្រួតពិនិត្យ
- ជ្រើសរើសក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល ដើម្បីធ្វើការត្រួតពិនិត្យគុណភាព

- ពិភាក្សា និងអនុម័តរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព
- ស្នើឡើងនូវវិធាន និងនីតិវិធីសម្រាប់លើកកម្ពស់គុណភាព
- លើកយោបល់ជូន **ន.គ.ស.** អំពីការដាក់លក្ខខណ្ឌ និង/ឬការរឹតត្បិតលើក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល
- លើកយោបល់ជូន **ន.គ.ស.** អំពីការផាកពិន័យ និង/ឬទណ្ឌកម្មរដ្ឋបាល ដែលអាចត្រូវបានដាក់លើក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល
- ផ្តល់យោបល់បច្ចេកទេសលើស្តង់ដាវិជ្ជាជីវៈជូន **ន.គ.ស.** តាមការចាំបាច់
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាពការងារជូន **ន.គ.ស.**
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ៦ ._**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **គ.ត.ស.អ.** ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៣
## ការត្រួតពិនិត្យគុណភាព
## ផ្នែកទី១
## កម្មវិធី និងវដ្តត្រួតពិនិត្យគុណភាព

**ប្រការ៧ ._**

កម្មវិធីត្រួតពិនិត្យគុណភាពត្រូវធ្វើឡើងដោយក្រុមត្រួតពិនិត្យ១(មួយ)ដងក្នុង១(មួយ)ឆ្នាំ និងអនុវត្តក្នុងចន្លោះចាប់ពីខែសីហា ដល់ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ ឬអាចប្រែប្រួលតាមស្ថានភាពជាក់ស្តែង។

ការត្រួតពិនិត្យគុណភាពរបស់ **គ.ត.ស.អ.** លើក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល ប្រព្រឹត្តទៅផ្អែកលើវដ្តត្រួតពិនិត្យគុណភាព។

ក្រុមហ៊ុនសវនកម្មដែលមានអតិថិជនជាសហគ្រាសទទួលខុសត្រូវជាសាធារណៈ មានវដ្តត្រួតពិនិត្យគុណភាព ៣(បី)ឆ្នាំម្តង។

ក្រុមហ៊ុនសវនកម្មដែលមានអតិថិជនមិនមែនជាសហគ្រាសទទួលខុសត្រូវជាសាធារណៈ មានវដ្តត្រួតពិនិត្យគុណភាព៦(ប្រាំមួយ)ឆ្នាំម្តង។

ករណីមានហានិភ័យ **គ.ត.ស.អ.** អាចធ្វើការត្រួតពិនិត្យគុណភាពដោយមិនគិតពីវដ្តត្រួតពិនិត្យគុណភាពឡើយ។

**ប្រការ៨ ._**

ត្រូវបានចាត់ទុកថាជាហានិភ័យ ចំពោះករណីដូចមានចែងក្នុងកថាខណ្ឌទី៥ នៃប្រការ៧ នៃប្រកាសនេះ ប្រសិនបើក្រុមហ៊ុនសវនកម្មស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

- ក្រុមហ៊ុនសវនកម្មធ្លាប់ទទួលរងការស៊ើបអង្កេត និងដាក់វិន័យកន្លងមក
- លទ្ធផលនៃការត្រួតពិនិត្យគុណភាពកន្លងមកបង្ហាញនូវចំណុចណាមួយដូចខាងក្រោម៖
    - ការមិនបំពេញតាមការតម្រូវនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តរបស់ប្រធានសវនករ និងបុគ្គលិកពាក់ព័ន្ធនឹងការងារសវនកម្ម ឬការងារការអះអាង ឬ
    - ការរំលោភលើឯករាជ្យភាព ឬ

- ភាពខ្វះខាតក្នុងការបង្កើត ឬការអនុលោមតាមប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ក្រុមហ៊ុនសវនកម្ម

- ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលពុំបានកែលម្អកំហុសដែលបានរកឃើញកន្លងមក
- ត្រូវចាត់ទុកថាមានហានិភ័យផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល និង/ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ផ្នែកទី២
## លក្ខខណ្ឌនៃការជ្រើសតាំង និងមុខងារភារកិច្ចរបស់ក្រុមត្រួតពិនិត្យ

**ប្រការ៩ ._**

ការត្រួតពិនិត្យគុណភាពត្រូវធ្វើឡើងដោយក្រុមត្រួតពិនិត្យ ដែលមានប្រធានមួយរូប និងសមាជិកមួយចំនួន។

សមាជិកក្រុមត្រួតពិនិត្យអាចជាមន្ត្រីរបស់ **ន.គ.ស.** និងអាចជ្រើសរើសអ្នកជំនាញដែលមិនមែនជាមន្ត្រីរបស់ **ន.គ.ស.**។

ការជ្រើសរើសសមាជិកក្រុមត្រួតពិនិត្យ និងការអនុវត្តការងាររបស់ក្រុមត្រួតពិនិត្យ ត្រូវអនុវត្តគោលការណ៍មិនលម្អៀង និងឯករាជ្យភាព ដូចមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈជាធរមាន។

**ប្រការ១០ ._**

សមាជិកក្រុមត្រួតពិនិត្យដែលមិនមែនជាមន្ត្រីរបស់ **ន.គ.ស.** ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

- ការអប់រំវិជ្ជាជីវៈសមស្រប
- បទពិសោធន៍វិជ្ជាជីវៈពាក់ព័ន្ធ
- ការបណ្តុះបណ្តាលលើការអនុវត្តការត្រួតពិនិត្យគុណភាព។

**ន.គ.ស.** អាចកំណត់គុណវុឌ្ឍិបន្ថែម តាមការចាំបាច់។

**ប្រការ១១ ._**

តួនាទី និងភារកិច្ចរបស់ប្រធាន និងសមាជិកក្រុមត្រួតពិនិត្យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ស.អ.**។

## ផ្នែកទី៣
## ដំណើរការនៃការត្រួតពិនិត្យគុណភាព

**ប្រការ១២ ._**

ការត្រួតពិនិត្យគុណភាព ត្រូវធ្វើឡើងនៅការិយាល័យគោលដើមរបស់ក្រុមហ៊ុនសវនកម្ម។

**គ.ត.ស.អ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលនូវព័ត៌មានជាអាទិ៍ដូចខាងក្រោម៖

- កាលបរិច្ឆេទ និងពេលវេលានៃការចុះត្រួតពិនិត្យគុណភាព យ៉ាងហោចណាស់៤៥(សែសិបប្រាំ)ថ្ងៃមុនកាលបរិច្ឆេទចុះត្រួតពិនិត្យគុណភាព
- សមាសភាពនៃក្រុមត្រួតពិនិត្យ យ៉ាងហោចណាស់២០(ម្ភៃ)ថ្ងៃមុនកាលបរិច្ឆេទចុះត្រួតពិនិត្យគុណភាព។

**ប្រការ១៣ ._**

ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលត្រូវផ្តល់ឯកសារតម្រូវឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់របស់ **គ.ត.ស.អ.** ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានបញ្ជីឈ្មោះសមាសភាពក្រុមត្រួតពិនិត្យស្របតាមប្រការ១២ នៃប្រកាសនេះ។

**ប្រការ១៤.-**

ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល អាចដាក់ពាក្យស្នើសុំជំទាស់ជាលាយលក្ខណ៍អក្សរដោយមានភស្តុតាងត្រឹមត្រូវ និងគ្រប់គ្រាន់មក **គ.ត.ស.អ.** ក្នុងករណីមានសមាជិកក្រុមត្រួតពិនិត្យរូបណាមិនអនុលោមតាមកថាខណ្ឌទី៣ នៃប្រការ៩ នៃប្រកាសនេះ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ក្រោយពីទទួលបានការជូនដំណឹងដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ។

**គ.ត.ស.អ.** អាចដកចេញនូវសមាជិកក្រុមត្រួតពិនិត្យម្នាក់ ឬច្រើននាក់ ប្រសិនបើពិនិត្យឃើញថាការស្នើសុំជំទាស់ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ មានភាពត្រឹមត្រូវ។ **គ.ត.ស.អ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ទៅក្រុមហ៊ុនសវនកម្មអំពីសមាសភាពថ្មីដែលត្រូវបានតែងតាំងជំនួសក្នុងក្រុមត្រួតពិនិត្យ។

**ប្រការ១៥.-**

ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវធ្វើឡើងចំពោះ៖

- ប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ក្រុមហ៊ុនសវនកម្ម
- ឯកសារសវនកម្ម និង/ឬឯកសារការអះអាងរបស់សវនករជារូបវន្តបុគ្គល។

ការត្រួតពិនិត្យ និងការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ក្រុមហ៊ុនសវនកម្មរួមមាន គោលនយោបាយ និងនីតិវិធីដែលមានធាតុសំខាន់ៗដូចខាងក្រោម៖

- ដំណើរការនៃការវាយតម្លៃហានិភ័យ
- អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ
- ការតម្រូវរបស់ក្រមសីលធម៌វិជ្ជាជីវៈពាក់ព័ន្ធ
- ការទទួលយក និងការបន្តកិច្ចសន្យាសវនកម្ម ឬកិច្ចសន្យាការអះអាងជាមួយអតិថិជន
- ការអនុវត្តលើការងារសវនកម្ម ឬការងារការអះអាង
- ធនធាន និងការគ្រប់គ្រងបុគ្គលិក
- ព័ត៌មាន និងការប្រាស្រ័យទាក់ទង
- ដំណើរការនៃការត្រួតពិនិត្យ និងសកម្មភាពកែលម្អ
- ការរក្សាទុកឯកសារ។

ការត្រួតពិនិត្យ និងការវាយតម្លៃលើឯកសារសវនកម្ម និង/ឬឯកសារការអះអាងរបស់សវនករជារូបវន្តបុគ្គលធ្វើឡើងលើការងារសវនកម្ម និង/ឬការងារការអះអាងដែលសវនករជារូបវន្តបុគ្គលបានបញ្ចប់ និងបានចេញរបាយការណ៍សវនកម្ម ឬរបាយការណ៍ការអះអាងជូនដល់អតិថិជនរួចរាល់។

**ប្រការ១៦.-**

ក្នុងអំឡុងចុះត្រួតពិនិត្យគុណភាព ក្រុមហ៊ុនសវនកម្មត្រូវផ្តល់កិច្ចសហការជាមួយក្រុមត្រួតពិនិត្យ ដោយត្រូវ៖

- អនុញ្ញាតឱ្យក្រុមត្រួតពិនិត្យចូលត្រួតពិនិត្យលើគ្រប់ឯកសារដែលពាក់ព័ន្ធទាំងអស់ ស្របតាមស្តង់ដាវិជ្ជាជីវៈ
- ផ្តល់ពេលវេលាឱ្យក្រុមត្រួតពិនិត្យជួបសម្ភាសន៍ផ្ទាល់មាត់ ឬការសរសេរឆ្លើយតប ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងទៀត
- ផ្តល់ឯកសារសវនកម្ម ឬឯកសារការអះអាង ស្របតាមតម្រូវការនៃការស្នើសុំរបស់ក្រុមត្រួតពិនិត្យ
- ផ្តល់ទីកន្លែងសមរម្យ និងឯកសារសវនកម្ម ឬឯកសារការអះអាងឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់។

## ផ្នែកទី៤
## នីតិវិធីក្រោយចុះត្រួតពិនិត្យដល់ទីកន្លែង និងលទ្ធផលនៃការត្រួតពិនិត្យគុណភាព

**ប្រការ១៧.-**

ក្រោយបញ្ចប់ការត្រួតពិនិត្យគុណភាព ក្រុមត្រួតពិនិត្យត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព និងផ្ញើជូនក្រុមហ៊ុនសវនកម្ម ដើម្បីពិនិត្យនិងឯកភាព ឬមិនឯកភាពនូវចំណុចណាមួយ ឬទាំងស្រុងនៃការរកឃើញដែលក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលអនុវត្តមិនស្របតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាវិជ្ជាជីវៈពាក់ព័ន្ធជាធរមាន។

**ប្រការ១៨.-**

ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលត្រូវពិនិត្យ និងឆ្លើយតបជាលាយលក្ខណ៍អក្សរមកក្រុមត្រួតពិនិត្យអំពីសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាពក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសេចក្តីព្រាងរបាយការណ៍នេះ ដោយបញ្ជាក់ថាមាន ឬមិនមានឆន្ទៈក្នុងការឯកភាពលើលទ្ធផលនៃការរកឃើញ ដូចមានបង្ហាញក្នុងសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព។

**ប្រការ១៩.-**

បន្ទាប់ពីបានត្រួតពិនិត្យ និងវាយតម្លៃលើការឆ្លើយតបចំពោះសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាពដែលបានផ្ញើមកពីក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គល ស្របតាមប្រការ១៨ នៃប្រកាសនេះ **គ.ត.ស.អ.** ត្រូវ៖

- អនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព ក្នុងករណីក្រុមហ៊ុនសវនកម្មយល់ស្របលើសេចក្តីព្រាងរបាយការណ៍នេះ ឬ
- ចេញសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាពឡើងវិញ ដោយកែប្រែខ្លឹមសារនៃសេចក្តីព្រាងរបាយការណ៍មុន ក្នុងករណីការជំទាស់មានភាពសមហេតុផល និងត្រឹមត្រូវ។

ក្រោយអនុម័តរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ **ន.គ.ស.** ត្រូវបោះផ្សាយនិងផ្ញើរបាយការណ៍នេះជូនក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលដែលទទួលរងការត្រួតពិនិត្យគុណភាព។

**ប្រការ២០.-**

នីតិវិធីលម្អិតក្រោយការចុះត្រួតពិនិត្យគុណភាព ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ស.អ.**។

**ប្រការ២១.-**

លទ្ធផលនៃការត្រួតពិនិត្យគុណភាពត្រូវកំណត់តាមកម្រិតដែលសម្រេចដោយ **គ.ត.ស.អ.**។ កម្រិតនៃលទ្ធផលនេះមានជាអាទិ៍៖

- ការមិនមាន ឬមិនធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីសម្រាប់អនុវត្តការងារសវនកម្ម និង/ឬការងារការអះអាង
- ការមិនបានរៀបចំកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត សម្រាប់សវនករជារូបវន្តបុគ្គល និងបុគ្គលិកពាក់ព័ន្ធនឹងការងារសវនកម្ម និង/ឬការងារការអះអាង
- ការមិនបានរក្សាទុកឯកសារសវនកម្ម និង/ឬឯកសារការអះអាងឱ្យបានត្រឹមត្រូវ និងសមស្រប
- ការមិនបានរៀបចំឱ្យមានការប្រកាសអំពីឯករាជ្យភាពរបស់សវនករជារូបវន្តបុគ្គល និងបុគ្គលិកពាក់ព័ន្ធនឹងការងារសវនកម្ម និង/ឬការងារការអះអាងជាប្រចាំឆ្នាំ និងរាល់ពេលចុះកិច្ចសន្យាសវនកម្ម និង/ឬកិច្ចសន្យាការអះអាង
- ការមិនបានអនុវត្តស្របតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាវិជ្ជាជីវៈពាក់ព័ន្ធជាធរមាន។



8V

**ប្រការ២២.-**

**គ.ត.ស.អ.** ត្រូវផ្តល់របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាពជូន **ន.គ.ស.** និងអាចលើកសំណើអំពីវិធានការជូន **ន.គ.ស.**។ **ន.គ.ស.** អាចចាត់វិធានការណាមួយដូចខាងក្រោម៖

- ចុះត្រួតពិនិត្យឡើងវិញ
- ត្រួតពិនិត្យមុនបោះផ្សាយមតិសវនកម្ម ឬមតិការអះអាង
- ដាក់លក្ខខណ្ឌ និង/ឬការរឹតត្បិត
- ដាក់ទណ្ឌកម្មរដ្ឋបាល
- ព្យួរអាជ្ញាបណ្ណ
- ដកហូតអាជ្ញាបណ្ណ។

**ប្រការ២៣.-**

**ន.គ.ស.** ត្រូវផ្សព្វផ្សាយលទ្ធផលនៃការត្រួតពិនិត្យគុណភាពប្រចាំឆ្នាំជាសាធារណៈ ដែលលទ្ធផលនេះត្រូវបរិយាយជាអាទិ៍ វិសាលភាព ចំនួនក្រុមហ៊ុនសវនកម្មដែលត្រូវបានត្រួតពិនិត្យគុណភាព លទ្ធផលជារួមនៃការត្រួតពិនិត្យគុណភាព។

## ផ្នែកទី៥
## នីតិវិធីក្រោយការបោះផ្សាយរបាយការណ៍ស្តីពីលទ្ធផល នៃការត្រួតពិនិត្យគុណភាព

**ប្រការ២៤.-**

ករណី **ន.គ.ស.** បានដាក់លក្ខខណ្ឌ និង/ឬការរឹតត្បិត ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលត្រូវដោះស្រាយលក្ខខណ្ឌនិង/ឬការរឹតត្បិត និងត្រូវផ្ញើភស្តុតាងនិងការពន្យល់បន្ថែមជូន **ន.គ.ស.** ដើម្បីបញ្ជាក់ថាបានបំពេញតាមគ្រប់លក្ខខណ្ឌ និង/ឬការរឹតត្បិតទាំងអស់ ក្នុងរយៈពេលដែលបានកំណត់ដោយ **ន.គ.ស.** ផ្អែកតាមរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព។

ផ្អែកលើភស្តុតាង និងការពន្យល់ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ **ន.គ.ស.** ត្រូវ៖

- ជូនដំណឹងថាក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលបានបំពេញគ្រប់លក្ខខណ្ឌ និង/ឬការរឹតត្បិត
- ចាត់នីតិវិធីនៃការត្រួតពិនិត្យគុណភាពឡើងវិញ ប្រសិនបើ **ន.គ.ស.** រកឃើញថាក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលមិនបានបំពេញតាមលក្ខខណ្ឌ និង/ឬការរឹតត្បិតដែលបានកំណត់។

## ជំពូកទី៤
## ភារកិច្ចជាសារវន្តរបស់ក្រុមហ៊ុនសវនកម្ម សវនករជារូបវន្តបុគ្គល និងបុគ្គល បំពេញការងារក្នុងនាម គ.ត.ស.អ.

**ប្រការ២៥.-**

ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលត្រូវធានាថាឯកសារសវនកម្ម និង/ឬឯកសារការអះអាងមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់សម្រាប់ក្រុមត្រួតពិនិត្យ។ ក្នុងករណីក្រុមហ៊ុនសវនកម្មប្រើប្រាស់កម្មវិធីផ្នែកទន់សម្រាប់ការងារសវនកម្ម និង/ឬការងារការអះអាង ក្រុមហ៊ុនសវនកម្មត្រូវធានាថាកម្មវិធីនោះត្រូវបានរក្សាទុកឯកសារបានត្រឹមត្រូវនិងគ្រប់គ្រាន់ ដើម្បីអាចផ្តល់ឱ្យក្រុមត្រួតពិនិត្យធ្វើការត្រួតពិនិត្យគុណភាព និងផ្ទៀងផ្ទាត់បាន។

ក្រុមហ៊ុនសវនកម្ម និងសវនករជារូបវន្តបុគ្គលដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ ត្រូវផ្តល់ឯកសារបន្ថែមតាមការស្នើសុំរបស់ **គ.ត.ស.អ.** ឬក្រុមត្រួតពិនិត្យ តាមតម្រូវការចាំបាច់។

**ប្រការ២៦.-**

ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលត្រូវអនុវត្ត៖

- ស្តង់ដាអន្តរជាតិស្តីពីប្រព័ន្ធគ្រប់គ្រងគុណភាពសវនកម្ម ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាសវនកម្ម



ʆ

និងការអេះអាងអន្តរជាតិ និងស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈអន្តរជាតិសម្រាប់គណនេយ្យករជំនាញ នៃសហព័ន្ធគណនេយ្យករអន្តរជាតិ ដែលអនុម័តទទួលយកមកអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**

- គោលនយោបាយ នីតិវិធី ឬវិធីសាស្ត្រ ដែលត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនសវនកម្មសម្រាប់ការអនុវត្តការងារសវនកម្ម ឬការងារការអេះអាងឱ្យស្របតាមស្តង់ដាវិជ្ជាជីវៈជាធរមាន។

**ប្រការ២៧.-**

ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលមិនត្រូវផ្ញើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាព ឬខ្លឹមសារមួយផ្នែកណានៃរបាយការណ៍នេះទៅតតិយជនដោយគ្មានការអនុញ្ញាតពី **គ.ត.ស.អ.** ឡើយ។

**ប្រការ២៨.-**

**គ.ត.ស.អ.** និងគ្រប់បុគ្គលពាក់ព័ន្ធដែលអនុវត្តការងារក្នុងនាម **គ.ត.ស.អ.** ត្រូវគោរពការសម្ងាត់វិជ្ជាជីវៈដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៥
## កម្រៃនៃការត្រួតពិនិត្យគុណភាព

**ប្រការ២៩.-**

ក្រុមហ៊ុនសវនកម្មត្រូវបង់កម្រៃនៃការត្រួតពិនិត្យគុណភាពដូចខាងក្រោម៖

- ចំពោះក្រុមហ៊ុនសវនកម្មដែលមានអតិថិជនជាសហគ្រាសទទួលខុសត្រូវជាសាធារណៈ ត្រូវបង់កម្រៃ ៣០.០០០.០០០(សាមសិបលាន)រៀល។
- ចំពោះក្រុមហ៊ុនសវនកម្មដែលមានអតិថិជនមិនមែនជាសហគ្រាសទទួលខុសត្រូវជាសាធារណៈ ត្រូវបង់កម្រៃ ១៥.០០០.០០០(ដប់ប្រាំលាន)រៀល។

ការបង់កម្រៃនៃការត្រួតពិនិត្យគុណភាពត្រូវធ្វើឡើងក្នុងរយៈពេលមិនលើស៤៥(សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងស្តីពីការជ្រើសរើសក្រុមហ៊ុនសវនកម្មដើម្បីធ្វើការត្រួតពិនិត្យគុណភាព។

ករណីក្រុមហ៊ុនសវនកម្មខកខានបង់កម្រៃនៃការត្រួតពិនិត្យគុណភាព ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើនេះ ត្រូវទទួលរងទណ្ឌកម្មបន្ថែមដូចមានចែងក្នុងប្រការ៣៦ នៃប្រកាសនេះ។

**ប្រការ៣០.-**

កម្រៃនៃការត្រួតពិនិត្យគុណភាពដែលកំណត់ក្នុងប្រកាសនេះ ត្រូវបង់ចូលគណនីធនាគាររបស់ **ន.គ.ស.** និងត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយមក **ន.គ.ស.** ដោយមិនបង្អង់។

## ជំពូកទី៦
## ទណ្ឌកម្ម

**ប្រការ៣១.-**

ក្រុមហ៊ុនសវនកម្មដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តកម្មវិធីត្រួតពិនិត្យគុណភាព ត្រូវផាកពិន័យជាប្រាក់ ១០.០០០.០០០(ដប់លាន)រៀល។

**ប្រការ៣២.-**

សកម្មភាពដែលត្រូវបានចាត់ទុកថាជាអំពើរាំងស្ទះដល់ការត្រួតពិនិត្យគុណភាពដូចមានចែងក្នុងប្រកាសនេះមានជាអាទិ៍៖

- ការគេចវេសមិនទទួលយកការត្រួតពិនិត្យ ឬពន្យារពេលវេលាត្រួតពិនិត្យដោយមិនមានហេតុផលសមរម្យ

- ការព្យាយាមមិនឱ្យការត្រួតពិនិត្យគុណភាពត្រូវបានបញ្ចប់តាមផែនការ និងពេលវេលាដែលបានកំណត់
- ការមិនផ្តល់ ឬពន្យារពេលវេលាដោយមិនមានហេតុផលសមរម្យក្នុងការផ្តល់ឯកសារពាក់ព័ន្ធបន្ថែមតាមការស្នើសុំរបស់ក្រុមត្រួតពិនិត្យមុនពេល និងក្នុងអំឡុងត្រួតពិនិត្យគុណភាព តាមពេលដែលបានកំណត់
- ការមិនផ្តល់សិទ្ធិ និងឯករាជ្យភាពដល់ក្រុមត្រួតពិនិត្យ ដើម្បីត្រួតពិនិត្យលើប្រព័ន្ធគ្រប់គ្រងគុណភាព និង/ឬឯកសារសវនកម្ម និង/ឬឯកសារការអះអាងរបស់ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គល
- ការមិនចូលរួមក្នុងកិច្ចប្រជុំបើក និង/ឬកិច្ចប្រជុំបិទក្នុងអំឡុងចុះត្រួតពិនិត្យគុណភាពដល់ទីកន្លែង
- ការមិនឆ្លើយតប ឬផ្តល់ការឆ្លើយតបយឺតយ៉ាវមកក្រុមត្រួតពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យគុណភាពដែលក្រុមត្រួតពិនិត្យបានកំណត់ពេលវេលា។

**ប្រការ៣៣.-**

ក្រុមហ៊ុនសវនកម្មដែលធ្លាក់គុណភាព ជាកម្មវត្ថុនៃការផាកពិន័យ។ ការធ្លាក់គុណភាពត្រូវបានចាត់ជា៣(បី) កម្រិតដូចខាងក្រោម៖

១. ការធ្លាក់គុណភាពកម្រិតស្រាល ផ្អែកលើលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោម៖
- ភាពមិនគ្រប់គ្រាន់នៃឯកសារសវនកម្មរវាងក្រុមហ៊ុនសវនកម្មនិងអតិថិជន
- បញ្ហាតូចៗមួយចំនួនទាក់ទិននឹងស្តង់ដាអន្តរជាតិស្តីពីប្រព័ន្ធគ្រប់គ្រងគុណភាព ដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់ការអនុវត្តការងារសវនកម្ម
- ការយឺតយ៉ាវក្នុងការដាក់ឯកសារសម្រាប់ការត្រួតពិនិត្យគុណភាព
- ការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត ជាលើកដំបូងមិនបានពេញលេញ
- បំពានក្រមសីលធម៌កម្រិតស្រាលដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់ការអនុវត្តការងារសវនកម្ម។

២. ការធ្លាក់គុណភាពកម្រិតមធ្យម ផ្អែកលើលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោម៖
- បរាជ័យក្នុងការអនុវត្តការងារសវនកម្មលើចំណុចដដែល ដែលធ្លាប់បានត្រួតពិនិត្យពីមុន
- មិនមានផែនការសវនកម្មគ្រប់គ្រាន់
- ការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត ជាបន្តបន្ទាប់មិនបានពេញលេញ។

៣. ការធ្លាក់គុណភាពកម្រិតធ្ងន់ធ្ងរ ផ្អែកលើលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោម៖
- ការក្លែងបន្លំព័ត៌មានហិរញ្ញវត្ថុ និងសវនកម្ម
- ការសូកប៉ាន់ ឬឃុបឃិតដោយមិនត្រឹមត្រូវជាមួយអតិថិជន និងភាគីពាក់ព័ន្ធ
- ការប្រព្រឹត្តបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ។

**ប្រការ៣៤.-**

ក្រុមហ៊ុនសវនកម្មដែលធ្លាក់គុណភាព ត្រូវទទួលរងទណ្ឌកម្មដូចខាងក្រោម៖
- ធ្លាក់គុណភាពកម្រិតស្រាល ត្រូវកែលម្អលើចំណុចដែលបានរកឃើញដូចមានចែងក្នុងចំណុចទី១ នៃប្រការ៣៣ នៃប្រកាសនេះ។
- ធ្លាក់គុណភាពកម្រិតមធ្យម ត្រូវផាកពិន័យជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។
- ធ្លាក់គុណភាពកម្រិតធ្ងន់ធ្ងរ ត្រូវផាកពិន័យជាប្រាក់ ៤០.០០០.០០០(សែសិបលាន)រៀល។

**ប្រការ៣៥.-**

ក្រៅពីទណ្ឌកម្មដូចមានចែងក្នុងប្រការ៣៤ នៃប្រកាសនេះ **ន.គ.ស.** អាចដាក់ទណ្ឌកម្មរដ្ឋបាលណាមួយឬច្រើនលើក្រុមហ៊ុនសវនកម្មដែលធ្លាក់គុណភាពដូចខាងក្រោម៖

១. ចំពោះក្រុមហ៊ុនសវនកម្មដែលធ្លាក់គុណភាពកម្រិតស្រាល អាចត្រូវបានទទួលរងទណ្ឌកម្មរដ្ឋបាលបន្ថែមដូចខាងក្រោម៖



81

- ការព្រមានជាលាយលក្ខណ៍អក្សរ និងការដាក់កំហិតឱ្យធ្វើការកែតម្រូវ
- ការជូនដំណឹងជាសាធារណៈអំពីនាមករណ៍របស់ក្រុមហ៊ុនសវនកម្ម និងឈ្មោះសវនករជាវូបវន្តបុគ្គល និងការតម្រូវឱ្យបញ្ឈប់ការបន្តប្រព្រឹត្តល្មើសដដែលៗ ដែលបណ្តាលឱ្យមានកំហុសធ្ងន់ធ្ងរ
- ការតម្រូវឱ្យក្រុមហ៊ុនសវនកម្មៈ
  - ពង្រឹងសមត្ថភាពវិជ្ជាជីវៈដើម្បីធានាថាសវនករជារូបវន្តបុគ្គល និងបុគ្គលិកទទួលបានការបណ្តុះបណ្តាលជាក់លាក់ និងមានសមត្ថភាពសមស្រប
  - ធានាភាពគ្រប់គ្រាន់នៃចំនួនសវនករជារូបវន្តបុគ្គល ធនធាន និងបុគ្គលិក ដើម្បីធានាបាននូវគុណភាពសេវាសវនកម្ម និងសេវាការអះអាង។

២. ចំពោះក្រុមហ៊ុនសវនកម្មដែលធ្លាក់គុណភាពកម្រិតមធ្យមនិងកម្រិតធ្ងន់ធ្ងរ អាចត្រូវបានទទួលរងទណ្ឌកម្មរដ្ឋបាលបន្ថែមដូចខាងក្រោមៈ
- ការព្រមានជាលាយលក្ខណ៍អក្សរ និងការដាក់កំហិតឱ្យធ្វើការកែតម្រូវ
- ការជូនដំណឹងជាសាធារណៈអំពីនាមករណ៍របស់ក្រុមហ៊ុនសវនកម្ម និងឈ្មោះសវនករជារូបវន្តបុគ្គល និងតម្រូវឱ្យបញ្ឈប់ការបន្តប្រព្រឹត្តល្មើសដដែលៗ ដែលបណ្តាលឱ្យមានកំហុសធ្ងន់ធ្ងរ
- ការតម្រូវឱ្យក្រុមហ៊ុនសវនកម្មៈ
  - ពង្រឹងសមត្ថភាពវិជ្ជាជីវៈដើម្បីធានាថាសវនករជារូបវន្តបុគ្គល និងបុគ្គលិកទទួលបានការបណ្តុះបណ្តាលជាក់លាក់ និងមានសមត្ថភាពសមស្រប
  - ធានាភាពគ្រប់គ្រាន់នៃចំនួនសវនករជារូបវន្តបុគ្គល ធនធាន និងបុគ្គលិក ដើម្បីធានាបាននូវគុណភាពសេវាសវនកម្ម និងសេវាការអះអាង។
- ការតម្រូវឱ្យក្រុមហ៊ុនសវនកម្មដកហូត ឬផ្លាស់ប្តូរមតិសវនកម្ម ឬការអះអាងត្រឡប់មកវិញ ក្នុងករណីដែលរបាយការណ៍សវនកម្ម ឬរបាយការណ៍ការអះអាងមិនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាវិជ្ជាជីវៈពាក់ព័ន្ធជាធរមាន។
- ការព្យួរអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មសម្រាប់ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលក្នុងរយៈពេលមិនលើស៣(បី)ឆ្នាំ
- ការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មសម្រាប់ក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គល
- ការដាក់លក្ខខណ្ឌ និង/ឬការរឹតត្បឹតដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះ។

មុននឹងដាក់ទណ្ឌកម្មបន្ថែមដូចមានចែងក្នុងប្រការនេះ **ន.គ.ស.** ត្រូវផ្តល់ឱកាសឱ្យក្រុមហ៊ុនសវនកម្ម និង/ឬសវនករជារូបវន្តបុគ្គលធ្វើការបកស្រាយបំភ្លឺជាមុន។

**ប្រការ៣៦.-**

ក្នុងករណីក្រុមហ៊ុនសវនកម្មមិនបង់ប្រាក់ផាកពិន័យ និង/ឬប្រាក់កម្រៃនៃការត្រួតពិនិត្យគុណភាពក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ ទំហំប្រាក់ផាកពិន័យ និង/ឬប្រាក់កម្រៃនឹងត្រូវដំឡើងជាពីរដង។ ករណីខកខានបង់ប្រាក់ផាកពិន័យ និង/ឬប្រាក់កម្រៃលើសពី៩០(កៅសិប)ថ្ងៃ ទំហំប្រាក់ផាកពិន័យ និង/ឬប្រាក់កម្រៃនឹងត្រូវដំឡើងជាបីដង។ ករណីខកខានបង់ប្រាក់ផាកពិន័យ និង/ឬប្រាក់កម្រៃលើសពីរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ **ន.គ.ស.** ត្រូវព្យួរអាជ្ញាបណ្ណ ឬដកហូតអាជ្ញាបណ្ណ។

រយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ ៩០(កៅសិប)ថ្ងៃ និង១២០(មួយរយម្ភៃ)ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃដែលក្រុមហ៊ុនសវនកម្មបានទទួលលិខិតជូនដំណឹងផ្លូវការអំពីការបង់ប្រាក់ផាកពិន័យ និង/ឬការបង់កម្រៃនៃការត្រួតពិនិត្យគុណភាព។

**ប្រការ៣៧.-**

ករណីក្រុមហ៊ុនសវនកម្មមិនសុខចិត្តចំពោះការផាកពិន័យ ក្រុមហ៊ុនអាចដាក់ពាក្យបណ្តឹងតវ៉ាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## ធនធានហិរញ្ញវត្ថុ

**ប្រការ៣៨ .-**

**គ.គ.ស.អ.** ប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ **ន.គ.ស.** ដើម្បីបំពេញមុខងារនិងភារកិច្ចអនុលោមតាមប្រកាសនេះ និង/ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៣៩ .-**

ចំណូលធនធានហិរញ្ញវត្ថុដែលទទួលបានមកពីកម្រៃនៃការត្រួតពិនិត្យគុណភាព និងប្រាក់ពិន័យដូចដែលបានកំណត់ក្នុងប្រកាសនេះ ជាចំណូលផ្ទាល់របស់ **ន.គ.ស.** និងត្រូវបង់ចូលគណនីធនាគាររបស់ **ន.គ.ស.**។ ចំណូលនេះនឹងត្រូវប្រើប្រាស់សម្រាប់ជាគុណប្រយោជន៍ដល់ដំណើរការ **ន.គ.ស.** និង **គ.គ.ស.អ.** និង/ឬអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៤០ .-**

តាមការចាំបាច់ **ន.គ.ស.** អាចចេញគោលការណ៍ណែនាំ ឬវិធាននានាដើម្បីអនុវត្តប្រកាសនេះ។

**ប្រការ៤១ .-**

ប្រកាសលេខ៣៤០ សហវ.ក.ជ.គ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤២ .-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៣ រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ